# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# ការលុបបំបាត់ទាសភាពនៅក្នុងប្រទេសកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២

យើងខ្ញុំ សូមសម្តែងការព្រួយបារម្ភជាខ្លាំង ចំពោះរបាយការណ៍បង្ហាញពីការកើតឡើងយ៉ាងច្រើននៃការជួញដូរមនុស្សចូលមកក្នុងប្រទេសកម្ពុជា ដែលបានធ្វើឱ្យមានការធ្វើពលកម្មដោយបង្ខំ អំពើទាសភាព និងទារុណកម្មនៅតាមបរិវេណអគារនានា នៅក្នុងប្រទេស ។ ការរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ និងគណនីបណ្តាញសង្គមរបស់ជនរងគ្រោះជាច្រើន ដែលចងក្រងដោយអង្គការក្នុងស្រុកនិងអន្តរជាតិបង្ហាញថា មនុស្សរាប់ពាន់នាក់ដែលភាគច្រើនជាជនបរទេស ត្រូវបានជាប់ក្នុងស្ថានភាពទាំងអស់នេះ ។ យើងខ្ញុំ សូមស្នើសុំឱ្យអាជ្ញាធរចាត់វិធានការរួមគ្នា និងប្រកបដោយប្រសិទ្ធភាព ក្នុងការឆ្លើយតបទៅនឹងការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរទាំងនេះ ក៏ដូចជាស៊ើបអង្កេតភាពស្មុគស្មាញដែលត្រូវបានលើកឡើងរវាងអាជ្ញាធរ រដ្ឋ និងសហគ្រាសដែលប្រព្រឹត្តបទល្មើសផ្សេងៗ ។

ការរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ និងគណនីរបស់ជនរងគ្រោះ បង្ហាញថាការរំលោភបំពានទាំងនេះពាក់ព័ន្ធនឹងជនបរទេសដែលត្រូវបានចាប់ជំរិត លក់ ជួញដូរ ឬត្រូវបានបោកបញ្ឆោតឱ្យទទួលបានការងារនៅក្នុងប្រទេសកម្ពុជា ។ នៅពេលមកដល់ប្រទេសកម្ពុជា ពួកគេត្រូវបានឃុំខ្លួនក្នុងបរិវេណអគារធំៗ និងត្រូវបង្ខំឱ្យធ្វើការដែលជាញឹកញាប់ជាការងារទាក់ទងនឹងប្រតិបត្តិការបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណិត ដែលដាក់គោលដៅលើជនបរទេសរស់នៅខាងក្រៅប្រទេសកម្ពុជា ។ បុគ្គលិកដែលរត់គេចខ្លួន បានរាយការណ៍ថា ពួកគេបានប្រឈមមុខនឹងការគំរាមកំហែងទាំងផ្លូវកាយ និងផ្លូវចិត្ត និងអំពើហិង្សាដែលប្រព្រឹត្តដោយអ្នកចាប់បង្ខាំងពួកគេ ។ របាយការណ៍មួយចំនួនបង្ហាញថា ភាគច្រើននៃបរិវេណអគារទាំងនោះគឺស្ថិតនៅក្នុងខេត្តព្រះសីហនុ ប៉ុន្តែក៏មានការរំលោភបំពានស្រដៀងគ្នានេះ ដែលត្រូវបានគេរាយការណ៍ថាកើតឡើងនៅក្នុងរាជធានីភ្នំពេញ ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តផ្សេងទៀតផងដែរ ។

ការពិតដ៏គ្រោះថ្នាក់មួយនេះ ត្រូវបានទទួលស្គាល់ដោយស្ថានទូតបរទេសជាច្រើន ។ ប្រទេសឥណ្ឌូណេស៊ីបានចេញការព្រមានមួយទាក់ទងនឹងស្ថានភាពក្នុងខែមករា ឆ្នាំ២០២១ ។ ប្រទេសវៀតណាមបានព្រមានដល់ប្រជាពលរដ្ឋរបស់ខ្លួនអំពីប្រតិបត្តិការបែបនេះនៅក្នុងខែមិថុនា ឆ្នាំ២០២១ ។ រដ្ឋាភិបាលថៃបានចេញការព្រមាននៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ។ ស្ថានទូតប៉ាគីស្ថាន ក៏បានរាយការណ៍ថាខ្លួនបានជួយសង្គ្រោះប្រជាពលរដ្ឋបួននាក់ក្នុងខែមករា ឆ្នាំ២០២២ ។ ហើយស្ថានទូតចិនបានចេញផ្សាយសេចក្តីថ្លែងការណ៍ និងការព្រមានជាច្រើនទាក់ទងនឹងប្រតិបត្តិការទាំងនេះ ។ អាជ្ញាធរថៃក៏បានសម្តែងការព្រួយបារម្ភ ហើយថ្មីៗនេះពួកគេបានបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការជួយអន្តរាគមន៍ករណី ដែលប្រជាពលរដ្ឋថៃត្រូវបានគេជួញដូរ និងជាប់ក្នុងបរិវេណអគារទាំងនេះ ។

អ្នកសារព័ត៌មានក្នុងស្រុក និងអន្តរជាតិ ដើរតួយ៉ាងសំខាន់ក្នុងការបើកកកាយវិបត្តិសិទ្ធិមនុស្សទាំងនេះ ក៏ដូចជាការរាយការណ៍អំពីជនរងគ្រោះ ជនល្មើស និងស្ថាប័នរដ្ឋដែលពាក់ព័ន្ធក្នុងប្រតិបត្តិការទាំងអស់នេះ ។ របាយការណ៍មួយចំនួនបានរាយការណ៍ពីការជាប់ពាក់ព័ន្ធនឹងឧកញ៉ាខ្មែរដ៏ល្បីឈ្មោះមួយរូប និងសមាជិកព្រឹទ្ធសភានៃគណបក្សកាន់អំណាចមួយរូប ដែលជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការមួយចំនួន ។

ខណៈដែលអាជ្ញាធរកម្ពុជាមួយចំនួនបានឆ្លើយតបនឹងពាក្យបណ្ដឹងរបស់បុគ្គលមួយចំនួនតូច ក៏វិបត្តិនេះនៅតែមិនអាចដោះស្រាយម្ដងមួយករណីបែបនេះបានទេ ។ ការឆ្លើយតបរួមគ្នា និងកំណត់គោលដៅច្បាស់លាស់ គឺត្រូវការជាបន្ទាន់ពីអាជ្ញាធរកម្ពុជា អង្គការជាតិ និងអន្តរជាតិ ស្ថាប័នអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលផ្សេងទៀត ដើម្បីឆ្លើយតបទៅនឹងទំហំដ៏ធំនៃវិបត្តិនេះ ។ យើងខ្ញុំ ស្នើសុំឱ្យអាជ្ញាធរកម្ពុជាបំពេញការទទួលខុសត្រូវរបស់ខ្លួនដើម្បីស៊ើបអង្កេតឱ្យបានពេញលេញនូវការរំលោភបំពាននៅក្នុងប្រទេសរបស់ខ្លួន ព្រមទាំងលុបបំបាត់រាល់ទីតាំងទាំងអស់ដែលជាប់ទាក់ទងនឹងល្បែងស៊ីសងខុសច្បាប់ និងប្រតិបត្តិការបោកបញ្ឆោត ក៏ដូចជាការបង្ខំឱ្យធ្វើពលកម្ម ទាសភាព ឬការធ្វើទារុណកម្ម ។ សូមធានាផងដែរថា អ្នកដែលជាប់បង្ខាំងខ្លួនត្រូវបានដោះលែង និងផ្ដល់សុវត្ថិភាពជូនពួកគាត់ ហើយកាត់ទោសអ្នកទទួលខុសត្រូវទាំងអស់តាមច្បាប់កម្ពុជា ។

ការបន្តឱ្យកើតមានឡើងនៃប្រតិបត្តិការទាំងនេះគឺជាសោកនាដកម្មមួយ ហើយយើងពិតសោកស្ដាយយ៉ាងខ្លាំងដែលប្រទេសកម្ពុជាកំពុងត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ភាពអមនុស្សធម៌បែបនេះ ។ តួអង្គដែលពាក់ព័ន្ធទាំងអស់ត្រូវតែធានាភ្លាមៗថា គ្មានអ្នកណាម្នាក់ត្រូវប្រឈមនឹងអំពើទាសភាព ឬការធ្វើទារុណកម្ម នៅក្នុងប្រទេសកម្ពុជាឡើយ ៕

**សេចក្តីថ្លែងការណ៍ចូលរួមគាំទ្រដោយ៖**

1. ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
2. សមាគមអ្នកបម្រើការងារតាមផ្ទះ (ADW)
3. Asian Forum for Human Rights and Development (FORUM-ASIA)
4. Bytes for All, Pakistan
5. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
6. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
7. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
8. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
9. Centre for Human Rights and Development, Mongolia
10. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
11. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
12. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
13. មជ្ឈមណ្ឌលកម្ពុជាសម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យ (CCIM)
14. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)
15. បណ្ដាញយុវជនកម្ពុជា (CYN)
16. Defense of Human Rights & Public Service Trust, Pakistan
17. អង្គការសមធម៌កម្ពុជា (EC)

18. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)

19. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)

20. Initiativ Kambodja (IK)

21. International Justice Mission (IJM)

22. អង្គការ ម្លប់តាប៉ាង

23. គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ (និកហ្វិក)

24. Odhikar, Bangladesh

25. អង្គការស្ពានសន្តិភាព (PBO)

26. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP-Center)

27. People's Empowerment Foundation, Thailand

28. អង្គការសមាគមធាងត្នោត (STT)

29. Society for the Protection of the Rights of the Child (SPARC), Pakistan

30. អង្គការតម្លាភាពកម្ពុជា (TI)

31. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញា លុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (NGO-CEDAW)

32. Suara Rakyat Malaysia (SUARAM), Malaysia

33. Women´s Rehabilitation Centre (WOREC), Nepal

34. Think Centre, Singapore

35. Banglar Manabadhikar Suraksha Mancha (MASUM), India

៣៦. Progressive Voice, Myanmar

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

- លោក អំ សំអាត នាយកផ្នែកកិច្ចការទូទៅនៃអង្គការ លីកាដូ, លេខទូរស័ព្ទ៖ (+855) 10 327 770 (ភាសាខ្មែរ)
- លោក Jake Sims នាយកប្រចាំប្រទេសនៃអង្គការ International Justice Mission, លេខទូរស័ព្ទ៖ (+855) 12 901 446 (ភាសាអង់គ្លេស)